ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃបេឡាជាតិសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ តាមរយៈការកំណត់យន្តការ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជី ការបង់ភាគទាន អត្រាភាគទាន អត្រាសមាច័យ ការទាមទារ និងការផ្តល់តាវកាលិក។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរាប់បញ្ចូលទាំងបុគ្គលដែលធ្វើការចាប់ពី២(ពីរ)កន្លែងឡើងទៅ។

**មាត្រា៣ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

| | |
|---|---|
| កម្មករនិយោជិត | សំដៅដល់កម្មករនិយោជិតគ្រប់ប្រភេទនិងគ្រប់សញ្ជាតិនៃវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលរួមមានបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ |
| ប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន | សំដៅដល់ផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេលមិនលើសពី១២០(មួយរយម្ភៃ)ខែចុងក្រោយមុនកាលបរិច្ឆេទមានសិទ្ធិទាមទារតាវកាលិកផ្នែកប្រាក់សោធន។ |
| ប្រាក់ឈ្នួលជាប់ភាគទាន | សំដៅដល់ប្រាក់ឈ្នួលមុនកាត់ពន្ធរបស់កម្មករនិយោជិតដែលត្រូវយកមកគណនាសម្រាប់ការបង់ភាគទាន។ |
| ប្រាក់ស្នើសុំជាប់ភាគទាន | សំដៅដល់ប្រាក់ដែលសមាជិក **ប.ស.ស.** បានស្នើសុំសម្រាប់ការគណនាភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត។ |
| ភាគទានផ្នែកប្រាក់សោធន | សំដៅដល់ប្រាក់ដែលសមាជិក **ប.ស.ស.** និងនិយោជកបានបង់មក **ប.ស.ស.** ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដែលជាទូទៅគិតជាភាគរយនៃប្រាក់ឈ្នួលរបស់សមាជិកម្នាក់ៗ ទុកសម្រាប់ការចំណាយក្នុងការផ្តល់តាវកាលិកដល់សមាជិក និងការចំណាយប្រតិបត្តិការនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។ |
| មតិក | ទ្រព្យសម្បត្តិជាកេរទាំងឡាយដែលបុគ្គលម្នាក់(មតកជន)បានបន្សល់ទុកក្រោយពេលស្លាប់។ |

| | |
|---|---|
| មតកជន | ជនដែលបានស្លាប់ទៅហើយ។ មតកជនក្នុងអនុក្រឹត្យនេះ សំដៅដល់សោធនិកជរាភាព ទុព្វលភាព ឬសមាជិក **ប.ស.ស.** ទទួលមរណភាព។ |
| របបសន្តិសុខសង្គមផ្នែកប្រាក់សោធន តាមរបបភាគទានដោយស្ម័គ្រចិត្ត | សំដៅដល់របបសន្តិសុខសង្គមផ្នែកសោធនដែលសមាជិកជាប់កាតព្វកិច្ចក្នុងរបបភាគទានកាតព្វកិច្ចស្ម័គ្រចិត្តបង់ក្នុងករណី៖<br>១) សមាជិក **ប.ស.ស.** ដែលបាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបន្ត។<br>២) សមាជិក **ប.ស.ស.** ដែលមានអាយុ៦០(ហុកសិប)ឆ្នាំ និងមានបំណងបង់ភាគទានបន្តដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែង ដែលសាមីជនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច។<br>៣) សមាជិក **ប.ស.ស.** ដែលមានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច និងដែលការបង់ភាគទានក្នុងផ្នែកនេះត្រូវអនុវត្តចំពោះតែចំណែកនៃប្រាក់ឈ្នួលដែលខ្ពស់ជាងប្រាក់ឈ្នួលពិតានតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញក្នុង **ប.ស.ស.** ឬអាចចូលរួមជាមួយប្រតិបត្តិករផ្សេង។ |
| វិភាជន៍ជរាភាព | សំដៅដល់ប្រាក់ឧបត្ថម្ភដែលបើកផ្តល់ជូនដល់សមាជិក **ប.ស.ស.** តែម្តងគត់ នៅពេលសាមីជនមិនបានបំពេញលក្ខខណ្ឌទទួលបានសោធនជរាភាព។ |
| សន្តតិជន | សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិនិងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម ដែលមានចែងនៅក្នុងទម្រង់នៃការស្នើសុំចូលរួមដោយស្ម័គ្រចិត្តតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។ |
| សន្តតិកម្ម | ការផ្ទេរនូវសិទ្ធិនិងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈ ដែលមានកំណត់ក្នុងអនុក្រឹត្យនេះ។ |
| អវសិដ្ឋ | ការកាលិកដែលខកខានមិនបានទាមទារក្នុងករណីប្រធានសក្តិ។ |

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

បេឡាជាតិសន្តិសុខសង្គម ដែលហៅកាត់ថា **ប.ស.ស.** គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនដូចមានចែងនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៣
## លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីក្នុងរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

**មាត្រា៥ .-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលប្រើប្រាស់កម្មករនិយោជិតចាប់ពី១(មួយ)នាក់ឡើង ត្រូវមានកាតព្វកិច្ចចុះបញ្ជីក្នុង **ប.ស.ស.** ផ្នែកប្រាក់សោធនក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន លើកលែងតែសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងាររួចហើយ។

ទម្រង់និងបែបបទនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានដូចមានចែងនៅក្នុងមាត្រា៥នៃអនុក្រឹត្យនេះត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិតក្នុង**ប.ស.ស.** យ៉ាងយូរ៣(បី)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងារ លើកលែងតែកម្មករនិយោជិតដែលបានចុះបញ្ជីរួចហើយ។ ការចុះបញ្ជីកម្មករនិយោជិតត្រូវអនុលោមតាមទិន្នន័យក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់កម្មករនិយោជិតបរទេស។

នីតិវិធី ទម្រង់និងបែបបទនៃការចុះបញ្ជី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧ .-**

**ប.ស.ស.** ត្រូវចេញបណ្ណសមាជិកដល់កម្មករនិយោជិតទាំងអស់ដែលបានចុះបញ្ជីដោយអនុលោមតាមទិន្នន័យក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែនសម្រាប់តែកម្មករនិយោជិតបរទេសប៉ុណ្ណោះ។

បណ្ណសមាជិក **ប.ស.ស.** ត្រូវផ្តល់ជូនដោយឥតគិតថ្លៃ។ ក្នុងករណីបាត់ ឬខូចខាត សមាជិក **ប.ស.ស.** ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន ឬ **ប.ស.ស.** និងស្នើសុំបណ្ណទុតិយតាយ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

បែបបទនិងនីតិវិធីនៃការផ្តល់បណ្ណទុតិយតានៃបណ្ណសមាជិក **ប.ស.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៤
## អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទាន របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

**មាត្រា៨ .-**

ភាគទានផ្នែកប្រាក់សោធន ជាបន្ទុករួមគ្នារវាងនិយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។ សម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំដំបូង ភាគទាននេះត្រូវកំណត់ក្នុងអត្រាស្មើនឹង៤%(បួនភាគរយ)នៃប្រាក់ឈ្នួលជាប់ភាគទានដូចដែលបានកំណត់ខាងក្រោម៖

- ២%(ពីរភាគរយ)ជាបន្ទុកនិយោជក
- ២%(ពីរភាគរយ) ជាបន្ទុកកម្មករនិយោជិត។

ក្នុងករណីដែលសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយបណ្ណបរទេស ប្រាក់ឈ្នួលប្រចាំខែត្រូវគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់មធ្យមប្រចាំខែដោយផ្អែកតាមអត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជាដែលជូនដំណឹងដោយ **ប.ស.ស.**។

ប្រាក់ឈ្នួលជាប់ភាគទានដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា៩ .-**

ការបង់ភាគទានផ្នែកប្រាក់សោធនត្រូវធ្វើឡើងជាប្រចាំខែ។ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលនិងបង់ភាគទានផ្នែកប្រាក់សោធនដែលជាចំណែករបស់ខ្លួន និងជាចំណែករបស់កម្មករនិយោជិតមកក្នុងគណនី **ប.ស.ស.** នៅធនាគារដៃគូ យ៉ាងយូរត្រឹមថ្ងៃទី១៥(ដប់ប្រាំ)នៃខែបន្ទាប់។

ក្នុងករណីនិយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន មានលទ្ធភាពបង់ភាគទានប្រចាំឆ្នាំត្រូវស្នើសុំមក **ប.ស.ស.**។ ការបង់ភាគទានប្រចាំឆ្នាំនេះ ត្រូវធ្វើឡើងនៅខែបន្ទាប់គិតចាប់ពីកាលបរិច្ឆេទនៃខែដែលបានស្នើសុំបង់ភាគទាន។ ការបង់ភាគទានធ្វើឡើងជាប្រចាំឆ្នាំ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានតាមឆ្នាំនៃប្រតិទិន។ **ប.ស.ស.** ត្រូវធ្វើការកែតម្រូវចំនួនភាគទាននៅដើមឆ្នាំបន្ទាប់។

**មាត្រា១០ .-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបង់ភាគទានប្រចាំខែ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់មក **ប.ស.ស.** យ៉ាងយូរត្រឹមថ្ងៃទី២០(ម្ភៃ)នៃខែបន្ទាប់។

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបង់ភាគទានប្រចាំឆ្នាំ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទាំងអស់មក **ប.ស.ស.** តាមកាលកំណត់ដូចខាងក្រោម៖

១. ក្នុងករណីមិនមានចលនាចេញ-ចូលបុគ្គលិករបស់ខ្លួន និយោជកត្រូវរាយការណ៍រៀងរាល់១២(ដប់ពីរ)ខែម្តង។

២. ក្នុងករណីមានចលនាចេញ-ចូលបុគ្គលិករបស់ខ្លួន និយោជកត្រូវរាយការណ៍យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃបម្រែបម្រួល។

ទម្រង់និងបែបបទនៃការរាយការណ៍អំពីចំនួនកម្មករនិយោជិតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១១ .-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់សៀវភៅបើកប្រាក់ឬតារាងបើកប្រាក់ឈ្នួលជាទម្រង់អេឡិចត្រូនិចឬឯកសារបើកប្រាក់ផ្សេងទៀតតាមខែនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗមក **ប.ស.ស.** ដើម្បីត្រួតពិនិត្យតាមការស្នើសុំ។

**មាត្រា១២ .-**

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារមានកាតព្វកិច្ចជូនដំណឹងមក **ប.ស.ស.** រាល់ការបិទ ការព្យួរ ការប្តូរទីតាំងសហគ្រាស គ្រឹះស្ថាន ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃការបិទ ការព្យួរ ការប្តូរទីតាំងសហគ្រាស គ្រឹះស្ថាន ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក។

ទម្រង់និងបែបបទនៃការបិទ ការព្យួរ ការប្តូរទីតាំងសហគ្រាស គ្រឹះស្ថាន ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៥

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទាមទារ និងការផ្តល់តាមការលិក ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

**មាត្រា១៣ .-**

សមាជិក**ប.ស.ស.** ជាកម្មករនិយោជិត មានសិទ្ធិទទួលបានសោធនជរាភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
២.មានអាយុយ៉ាងតិច៦០(ហុកសិប)ឆ្នាំ និង
៣.បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច១២(ដប់ពីរ)ខែ។
សោធនជរាភាពដែលផ្ដល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជ | = | អស x បឈម |
| សជ | | ជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន |
| អស | | ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ |
| បឈម | | ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន។ |

ក្នុងករណីសមាជិក **ប.ស.ស.** ជាកម្មករនិយោជិត មិនបានបំពេញលក្ខខណ្ឌក្នុងចំណុច៣ នៃកថាខណ្ឌទី១ខាងលើ ត្រូវទទួលបានវិភាជន៍ជរាភាព។ វិភាជន៍ជរាភាពដែលផ្ដល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| វភជ | = | ផក (១+ សផ) |
| វភជ | | ជាវិភាជន៍ជរាភាពរបស់សាមីជនដែលត្រូវទទួលបាន |
| សផ | | ជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ |
| ផក | | ជាផលបូកចំនួនភាគទានដែលបានបង់សម្រាប់របបប្រាក់សោធន។ |

**មាត្រា១៤.-**

សមាជិក **ប.ស.ស.** ជាកម្មករនិយោជិត ដែលធ្លាក់ខ្លួនទុព្វលភាព មានសិទ្ធិទទួលបានសោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖
១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
២.បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែមុនកាលបរិច្ឆេទទទួលរងទុព្វលភាព។
សោធនទុព្វលភាពដែលផ្ដល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សទ | = | អស X បឈម |
| សទ | | ជាសោធនទុព្វលភាពរបស់សាមីជនដែលត្រូវទទួលបាន |
| អស | | ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ |
| បឈម | | ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន។ |

កម្រិតអប្បបរមានៃសោធនទុព្វលភាពត្រូវកំណត់ស្មើនឹង៤៥% (សែសិបប្រាំភាគរយ) នៃប្រាក់ឈ្នួលមធ្យមបង់ភាគទានរបស់សាមីជន។

**មាត្រា១៥.-**

សិទ្ធិវន្តនៃសោធនឧត្តរជីវី មានសិទ្ធិទទួលបានសោធនឧត្តរជីវី លុះត្រាតែមានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាព ឬទុព្វលភាព ឬសមាជិក **ប.ស.ស.** បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ។

សោធនឧត្តរជីវីដែលផ្ដល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជវ | = | ៥៥% x សជ ឬ ៥៥% x សទ |
| សជវ | | ជាសោធនឧត្តរជីវីដែលសិទ្ធិវន្តត្រូវទទួលបាន |
| សជ | | ជាសោធនជរាភាព |
| សទ | | ជាសោធនទុព្វលភាព។ |

ចំណែកសោធននគ្គរជីវី ត្រូវបានបែងចែកដូចខាងក្រោម៖

-សម្រាប់សហព័ទ្ធ៥០% (ហាសិបភាគរយ)

-សម្រាប់កូន៥០% (ហាសិបភាគរយ)

-ក្នុងករណីដែលសិទ្ធិវន្តមានតែសហព័ទ្ធ ឬកូន ត្រូវទទួលបាន១០០% (មួយរយភាគរយ)។

**មាត្រា១៦ .-**

សិទ្ធិវន្តនៃសោធននគ្គរជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសព នៅពេលដែលសោធនិកជរាភាព ឬទុព្វលភាពសាមីទទួលមរណភាព។ ប្រសិនបើករណីយកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធននគ្គរជីវី វិភាជន៍បូជាសពអាចត្រូវបានផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជាសពសាមីជនផ្ទាល់។

លក្ខខណ្ឌនៃការទទួលបានវិភាជន៍បូជាសពត្រូវកំណត់ដូចខាងក្រោម៖

- ជូនដំណឹងមក **ប.ស.ស.** អំពីមរណភាពរបស់សោធនិកជរាភាព ឬទុព្វលភាព ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទទទួលមរណភាព

- បំពេញទម្រង់ស្នើសុំវិភាជន៍បូជាសពដោយភ្ជាប់ជាមួយនូវសំបុត្រមរណភាព ឬឯកសារផ្សេងៗដែលទទួលស្គាល់ដោយ **ប.ស.ស.**។

**ប.ស.ស.** ត្រូវចេញសេចក្តីសម្រេចផ្តល់វិភាជន៍បូជាសព ក្នុងរយៈពេលមិនលើស២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំ។

នីតិវិធីនិងបែបបទនៃការផ្តល់តាវកាលិកវិភាជន៍បូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

**មាត្រា១៧ .-**

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌដើម្បីទទួលបានតាវកាលិកសោធនជរាភាពត្រូវបំពេញទម្រង់ទាមទារតាវកាលិកនេះ ក្នុងអំឡុងពេល៣(បី)ខែ មុនកាលបរិច្ឆេទដែលសាមីជនមានសិទ្ធិទាមទារ។ ក្នុងករណីសមាជិក **ប.ស.ស.** ដែលត្រូវទទួលបានវិភាជន៍ជរាភាព ត្រូវបំពេញទម្រង់ទាមទារវិភាជន៍ជរាភាពក្នុងអំឡុងពេល១(មួយ)ខែ ក្រោយពេលអាយុ៦០(ហុកសិប)ឆ្នាំ។

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌដើម្បីទទួលបានតាវកាលិកសោធនទុព្វលភាព ត្រូវបំពេញទម្រង់ទាមទារតាវកាលិកនេះ ក្នុងអំឡុងពេល១(មួយ)ខែ គិតចាប់ពីកាលបរិច្ឆេទធ្លាក់ខ្លួនទុព្វលភាព។ ក្នុងករណីដែលទុព្វលជនមិនមានលទ្ធភាពក្នុងការទាមទារតាវកាលិក ដោយសារមានភាពទ្រុឌទ្រោមធ្ងន់ធ្ងរ ការស្នើសុំត្រូវធ្វើដោយអ្នកតំណាងស្របច្បាប់នៃទុព្វលជននោះ។

សិទ្ធិវន្តនៃសោធននគ្គរជីវីត្រូវបំពេញទម្រង់ទាមទារតាវកាលិកនេះក្នុងអំឡុងពេល៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាព ឬទុព្វលភាព ឬសមាជិក **ប.ស.ស.** ដែលបានបង់ភាគទានយ៉ាងតិច៦០(ហុកសិប)ខែ។

សិទ្ធិវន្តនៃសោធននគ្គរជីវី ឬបុគ្គលដែលចាត់ចែងបូជាសពសោធនិកជរាភាព ឬទុព្វលភាពត្រូវបំពេញទម្រង់ទាមទារតាវកាលិកវិភាជន៍បូជាសពយ៉ាងយូរ៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទសោធនិកជរាភាពឬទុព្វលភាពទទួលមរណភាព។

តាវកាលិកសោធនជរាភាព ទុព្វលភាព និងសោធននគ្គរជីវី ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការទាមទារ។ ក្នុងករណីខកខានការទាមទារ ដោយករណីប្រធានសក្តិ សាមីជនអាចទាមទារអវសិដ្ឋ។ អវសិដ្ឋនេះត្រូវផ្តល់ជូនតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

ទម្រង់នៃការទាមទារតាវកាលិកនីមួយៗត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

# ជំពូកទី៦
# របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត

**មាត្រា១៨ .-**

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម មានសិទ្ធិស្នើសុំមក **ប.ស.ស.** ដើម្បីចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត៖

១.បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបង់ភាគទានបន្ត។

២.មានអាយុ៦០(ហុកសិប)ឆ្នាំ និងមានបំណងបង់ភាគទានបន្តដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែង ដែលសាមីជនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច។

៣.មានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច។ ប្រាក់ឈ្នួលពិតាន ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា១៩ .-**

សមាជិក **ប.ស.ស.** អាចស្នើសុំចុះបញ្ជីផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តនៅ **ប.ស.ស.** ដោយសាមីជនផ្ទាល់។ ទម្រង់និងបែបបទនៃការចុះបញ្ជីកម្មករនិយោជិតត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។ **ប.ស.ស.**ត្រូវចេញវិញ្ញាបនបត្ររដ្ឋបាល បញ្ជាក់អំពីអត្តសញ្ញាណសោធនស្ម័គ្រចិត្ត។

**មាត្រា២០ .-**

ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តជាបន្ទុកផ្ទាល់របស់សាមីជនដែលបានចុះបញ្ជីក្នុងផ្នែកនេះ។ អត្រាភាគទានផ្នែកនេះត្រូវកំណត់ស្មើនឹងអត្រាភាគទានតាមរបបភាគទានជាកាតព្វកិច្ច។ ចំនួនទឹកប្រាក់ជាប់ភាគទានត្រូវអនុវត្តតាមប្រាក់ស្នើសុំជាប់ភាគទានរបស់សាមីជនផ្ទាល់។

ប្រាក់ស្នើសុំជាប់ភាគទានសម្រាប់សមាជិក **ប.ស.ស.** ដែលបាត់បង់ការងារមុនអាយុ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបង់ភាគទានបន្ត ត្រូវកំណត់ស្មើនឹងប្រាក់ឈ្នួលមធ្យម៦(ប្រាំមួយ)ខែចុងក្រោយ គិតចាប់ពីកាលបរិច្ឆេទបាត់បង់ការងារ។

ចំពោះសមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច១ឬ២នៃមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តនីតិវិធីនៃការបង់ភាគទានក្នុងផ្នែកនេះយ៉ាងតិចចាប់ពី៦(ប្រាំមួយ)ខែឡើង។

ចំពោះសមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច៣នៃមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។

**មាត្រា២១ .-**

សមាជិក **ប.ស.ស.** ដែលបានចូលរួមក្នុងរបបប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តមានកាតព្វកិច្ចបង់ភាគទាន ដោយផ្អែកតាមលេខអត្តសញ្ញាណសោធនស្ម័គ្រចិត្តដែលចេញដោយ **ប.ស.ស.** មកក្នុងគណនី **ប.ស.ស.**នៅធនាគារដៃគូ។

យន្តការបង់ភាគទាននៃផ្នែកនេះត្រូវប្រើប្រាស់ដូចគ្នានឹងយន្តការបង់ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ។

**មាត្រា២២ .-**

សមាជិក **ប.ស.ស.**នៃផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវមានកាតព្វកិច្ចជូនដំណឹងមក **ប.ស.ស.** រាល់ការឈប់ ឬការព្យួរការបង់ភាគទាននៃផ្នែកនេះ យ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

ទម្រង់និងបែបបទនៃការស្នើសុំឈប់ឬព្យួរការបង់ភាគទានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គនាយក **ប.ស.ស.** ។

**មាត្រា២៣.-**

សមាជិក **ម.ស.ស.** ជាកម្មករនិយោជិតដែលបានចុះបញ្ជីក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ហើយបានបំពេញលក្ខខណ្ឌក្នុងចំណុច១ឬ២នៃមាត្រា១៨ នៃអនុក្រឹត្យនេះ មានសិទ្ធិទទួលបានសោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និងវិភាជន៍បូជាសព។

ការគណនាតារាកាលិកសោធនជរាភាព សោធនទុព្វលភាព និងសោធនឧត្តរជីវី ត្រូវអនុវត្តដូចផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច។

**មាត្រា២៤.-**

សមាជិក **ម.ស.ស.** ជាកម្មករនិយោជិត ដែលបានចុះបញ្ជីក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ហើយបានបំពេញលក្ខខណ្ឌក្នុងចំណុច៣នៃមាត្រា១៨នៃអនុក្រឹត្យនេះ មានសិទ្ធិទទួលបានតែសោធនជរាភាពតែមួយគត់ប៉ុណ្ណោះ។ សោធនជរាភាពត្រូវបែងចែកដូចខាងក្រោម៖

- ១/៣(មួយភាគបី)នៃចំនួនភាគទានដែលបានបង់សរុប ដោយរួមបញ្ចូលទាំងផលនៃការវិនិយោគ ត្រូវបើកផ្តល់ប្រាក់វិភាជន៍ជូនសោធនិកតែម្តងគត់នៅពេលចូលនិវត្តន៍
- ២/៣(ពីរភាគបី)នៃចំនួនភាគទានដែលបង់សរុបដែលរួមបញ្ចូលទាំងផលនៃការវិនិយោគ ត្រូវបើកផ្តល់ជាប្រចាំខែជូនសោធនិកតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជ | = | បស / ចខរ |
| ចខរ | = | (អយ-អច) x ១២ |
| ចខរ | | ចំនួនខែដែលសាមីជនរំពឹងរស់បានក្រោយអាយុចូលនិវត្តន៍ |
| សជ | | ជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន |
| បស | | ជាប្រាក់ដែលនៅសល់២/៣ នៃចំនួនប្រាក់ភាគទានដែលបានបង់សរុប ដោយបូកនឹងផលនៃការវិនិយោគ |
| អយ | | ជាអាយុរំពឹងទុក |
| អច | | ជាអាយុចូលនិវត្តន៍ដែលកំណត់ដោយច្បាប់។ |

អាយុរំពឹងទុកត្រូវអនុលោមតាមស្ថិតិដែលចេញដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

ក្រុមប្រឹក្សាភិបាលនៃ **ម.ស.ស.** ត្រូវកំណត់ផលនៃការវិនិយោគរបស់មូលនិធិប្រាក់សោធនតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញជាប្រចាំឆ្នាំ អនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម។

**មាត្រា២៥.-**

សន្តតិជននៃសមាជិក **ម.ស.ស.** ឬសន្តតិជននៃសោធនិកជរាភាពក្នុងផ្នែកប្រាក់សោធនតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភតែម្តងគត់។

ប្រាក់ដែលសន្តតិជនត្រូវទទួលបាន គឺជាចំនួនប្រាក់ភាគទានសរុបរបស់មតកជនបានបង់ភាគទានតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ ដោយរួមបញ្ចូលទាំងផលនៃការវិនិយោគនៃប្រាក់ភាគទានរបស់សមាជិក **ម.ស.ស.**ឬសោធនិកជរាភាពនៃប្រព័ន្ធហិរញ្ញប្បទានពេញលេញសរុបដែលនៅសល់ បន្ទាប់ពីការទទួលមរណភាពនៃមតកជន។

**មាត្រា២៦.-**

សមាជិក **ម.ស.ស.** ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច១ឬ២នៃមាត្រា១៨ នៃអនុក្រឹត្យនេះត្រូវបំពេញទម្រង់ទាមទារតារាកាលិកសោធនជរាភាព ទុព្វលភាព ឧត្តរជីវី និងវិភាជន៍បូជាសពដូចមានចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះ។

សមាជិក **ប.ស.ស.** ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច៣នៃមាត្រា១៨ នៃអនុក្រឹត្យនេះ ដើម្បីទទួលសោធនជរាភាពតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ ត្រូវបំពេញទម្រង់ទាមទារតាវកាលិកសោធនជរាភាពក្នុងអំឡុងពេល៣(បី)ខែមុនកាលបរិច្ឆេទដែលសាមីជនមានសិទ្ធិទាមទារ។

សន្តតិជននៃសមាជិក **ប.ស.ស.** ឬសោធនិកជរាភាពផ្នែកប្រាក់សោធនតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ ត្រូវបំពេញទម្រង់ទាមទារមត៌ក យ៉ាងយូរ៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃមរណភាពរបស់មតកជន។

តាវកាលិកសោធនជរាភាព ទុព្វលភាព និងសោធនឧត្តរជីវី ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការទាមទារ។ ក្នុងករណីខកខានការទាមទារដោយករណីប្រធានសក្តិ សាមីជនអាចទាមទារអវសិដ្ឋ។ អវសិដ្ឋនេះត្រូវផ្តល់ជូនតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

ទម្រង់នៃការទាមទារតាវកាលិកនីមួយៗត្រូវកំណត់ដោយអគ្គនាយក **ប.ស.ស.**។

## ជំពូកទី៧
## សមាចិធាន

**មាត្រា២៧ .-**

ប្រាក់សោធននៃតាវកាលិក សោធនជរាភាព សោធនទុព្វលភាព និងសោធនឧត្តរជីវី ត្រូវគណនាជាប្រចាំខែ។ **ប.ស.ស.** ត្រូវរៀបចំបើកផ្តល់តាវកាលិកប្រចាំខែផ្នែកប្រាក់សោធនជាអឌ្ឍមាស ដោយការបើកជាអឌ្ឍមាសទី១ យ៉ាងយូរនៅថ្ងៃទី១៥(ដប់ប្រាំ)នៃខែនីមួយៗ និងអឌ្ឍមាសទី២ យ៉ាងយូរនៅថ្ងៃទី៣០(សាមសិប)នៃខែនីមួយៗ។ ប្រសិនបើកាលបរិច្ឆេទនៃការចូលនិវត្តន៍មិនស្ថិតចំថ្ងៃដើមខែ ថ្ងៃដែលនៅសល់ត្រូវបូកបញ្ចូលទៅខែបន្ទាប់។

**មាត្រា២៨ .-**

ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.** ត្រូវមានការកិច្ចក្នុងការវាយតម្លៃឬសម្រេចអំពីស្ថានភាពទុព្វលភាព។ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា២៩ .-**

**ប.ស.ស.** ត្រូវធ្វើការសិក្សា វិភាគវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន យ៉ាងយូរ៥(ប្រាំ)ឆ្នាំ ម្តង។ **ប.ស.ស.**មានសិទ្ធិស្នើសុំទិន្នន័យដែលទាក់ទងនឹងការវិភាគវាយតម្លៃហានិភ័យហិរញ្ញវត្ថុពីស្ថាប័ន ឬ អង្គភាពដែលពាក់ព័ន្ធ។

**មាត្រា៣០ .-**

តាវកាលិកផ្នែកប្រាក់សោធន ត្រូវធ្វើការកែសម្រួលជារៀងរាល់ឆ្នាំ ផ្អែកតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** អនុលោមតាមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការរបស់ក្រសួងផែនការ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការប្រចាំឆ្នាំត្រូវគណនាដោយយកផលបូកនៃសន្ទស្សន៍រៀងរាល់ខែក្នុងឆ្នាំចែកនឹងដប់ពីរ។

ការកែសម្រួលតាវកាលិកផ្នែកប្រាក់សោធនត្រូវធ្វើឡើងនៅឆ្នាំបន្ទាប់ គិតចាប់ពីសាមីជនបើកប្រាក់សោធននៅឆ្នាំដំបូង។ ការកែសម្រួលត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

$$\text{តវ}_{\text{ន}} = \text{តវ}_{\text{ន-១}}\ (\text{១+ សជ}_{\text{ន}})$$

$\text{តវ}_{\text{ន}}$ ជាតាវកាលិកដែលត្រូវកែសម្រួលនៅក្នុងឆ្នាំបន្ទាប់

$\text{តវ}_{\text{ន-១}}$ ជាតាវកាលិកដែលបានកែសម្រួលក្នុងឆ្នាំមុន

$\text{សជ}_{\text{ន}}$ ជាសន្ទស្សន៍ថ្លៃទំនិញក្នុងឆ្នាំបន្ទាប់។

**មាត្រា៣១ .-**

សមាជិក **ប.ស.ស.** ដែលធ្វើការងារចាប់ពី ២ (ពីរ)កន្លែងឡើងទៅ ត្រូវបង់ភាគទានក្នុងខែតែមួយ។ ឆ្នាំភាគទានត្រូវគណនាដោយរាប់បញ្ចូលចំនួនខែទាំងអស់ដែលសមាជិក **ប.ស.ស.** បានបង់ភាគទាន។

**មាត្រា៣២ .-**

អត្រាសមាច័យសោធនជរាភាព និងអត្រាសមាច័យសោធនទុព្វលភាព ត្រូវកំណត់ស្មើ១,៧៥% (មួយក្បៀសចិតសិបប្រាំភាគរយ) សម្រាប់១៥(ដប់ប្រាំ)ឆ្នាំភាគទានដំបូង និង១,២៥%(មួយក្បៀសម្ភៃប្រាំភាគរយ) សម្រាប់ឆ្នាំភាគទានបន្តបន្ទាប់។

ចំពោះសមាជិក **ប.ស.ស.** ដែលជាកម្មករនិយោជិតដែលមានចែងក្នុងចំណុច១ឬ២នៃមាត្រា២០ នៃអនុក្រឹត្យនេះ ឆ្នាំភាគទានដែលត្រូវគណនាអត្រាសមាច័យសោធនជរាភាព និងសោធនទុព្វលភាព ត្រូវរាប់បញ្ចូលទាំងរបបភាគទានជាកាតព្វកិច្ច និងទាំងរបបភាគទានដោយស្ម័គ្រចិត្ត។

**មាត្រា៣៣ .-**

កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនទាំងរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

**មាត្រា៣៤ .-**

អត្រាភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ត្រូវបានកំណត់តាមវិធីសាស្ត្របុព្វលាភជណ្តើរ ដូចខាងក្រោម៖

- ដំណាក់កាលទី១ ៖ ភាគទានត្រូវកំណត់ស្មើនឹង៤%(បួនភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទាន ឬប្រាក់ស្នើសុំជាប់ភាគទានក្នុងរយៈពេល៥(ប្រាំ)ឆ្នាំដំបូង គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាន ដូចមានចែងក្នុងមាត្រា៣៣ខាងលើ
- ដំណាក់កាលទី២ ៖ ភាគទានត្រូវកំណត់ស្មើនឹង៨%(ប្រាំបីភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទាន ឬប្រាក់ស្នើសុំជាប់ភាគទានក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីដំណាក់កាលទី១
- ដំណាក់កាលទី៣៖ អត្រាភាគទានត្រូវដំឡើង២,៧៥%(ពីរក្បៀសចិតសិបប្រាំភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទានឬប្រាក់ស្នើសុំជាប់ភាគទាន ក្នុងរយៈពេល១០(ដប់)ឆ្នាំ និងដំណាក់កាល១០(ដប់)ឆ្នាំបន្តបន្ទាប់។

ការកែសម្រួលវិធីសាស្ត្រនៃការកំណត់អត្រាភាគទានខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ដោយមានការគាំទ្រពីនិយ័តករសន្តិសុខសង្គម និងមានការយល់ព្រមពីក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៨
## ទោសប្បញ្ញត្តិ

**មាត្រា៣៥ .-**

ជនដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយណានៃអនុក្រឹត្យនេះ នឹងត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបទប្បញ្ញត្តិជាធរមានដទៃផ្សេងទៀត។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .-**

សមាជិក **ប.ស.ស.** ជាកម្មករនិយោជិតមានសិទ្ធិទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ ត្រូវបំពេញលក្ខខណ្ឌគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការជំបូង នៃផ្នែកប្រាក់សោធនដូចខាងក្រោម៖

- មានអាយុលើសពី៣០(សាមសិប)ឆ្នាំ
- បានបង់ភាគទានយ៉ាងតិច២៤(ម្ភៃបួន)ខែ ក្នុងរយៈពេល៣៦(សាមសិបប្រាំមួយ)ខែ។

សោធនជរាភាពអយ្យកប្បញ្ញត្តិដែលផ្តល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

| | | |
|---|---|---|
| សជអ | = | អស x បឈម |
| អស | = | ឆក+អប |
| អប | = | ( អសប- ៣០)/២ |
| សជអ | | ជាសោធនជរាភាពអយ្យកប្បញ្ញត្តិរបស់សាមីជនដែលត្រូវទទួលបាន |
| បឈម | | ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន |
| អស | | ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ |
| ឆក | | ជាចំនួនឆ្នាំដែលបានបង់ភាគទាន |
| អប | | ជាចំនួនឆ្នាំដែលត្រូវបន្ថែមសម្រាប់សោធនជរាភាពអយ្យកប្បញ្ញត្តិ ដែលមានកម្រិតអតិបរមា១៥ឆ្នាំ |
| អសប | | ជាអាយុរបស់សមាជិក **ប.ស.ស.** ដែលចូលបម្រើការងារដំបូងគិតចាប់ពីកាលបរិច្ឆេទដំណើរការដំបូងនៃផ្នែកប្រាក់សោធន។ |

**មាត្រា៣៧ .-**

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដែលមានអាយុចាប់ពី៥៤(ហាសិបប្រាំបួន)ឆ្នាំឡើង គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការដំបូងនៃផ្នែកប្រាក់សោធន មានសិទ្ធិបង់ភាគទានបង្គ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៦នៃអនុក្រឹត្យនេះ ដើម្បីទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ។ ការបង់ភាគទានបង្គ្រប់សម្រាប់សោធនជរាភាពអយ្យកប្បញ្ញត្តិនេះជាបន្ទុកផ្ទាល់របស់សាមីជន។

**មាត្រា៣៨ .-**

សមាជិក **ប.ស.ស.** ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលចុះបញ្ជីក្នុងផ្នែកប្រាក់សោធននេះ ក៏ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារដែលកំពុងដំណើរការ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣៩ .-**

កាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៤០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកបេឡាជាតិសន្តិសុខសង្គម គ្រប់អង្គភាព ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីសម្រេចគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤០
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ